ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

តុលាការកំពូល
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ១១
ចុះថ្ងៃទី០៦-០២-២០០៤
សាលដីកាលេខ៖០១
ចុះថ្ងៃទី០៤-០១-២០០៦

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៦ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ៖

១- ឯកឧត្តម ... ប្រធាន
២- លោក ... ចៅក្រម
៣- លោក ... ចៅក្រម
៤- លោក ... ចៅក្រម
៥- លោក ... ចៅក្រម

ក្រឡាបញ្ជី
លោក ......
តំណាងមហាអយ្យការ
លោក .... ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ០១ (ង) ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១១ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៤ របស់តុលាការកំពូល។

**ពីបទ:** ប៉ុនប៉ងមនុស្សឃាតដោយគិតទុកជាមុន និងក្រុមជនប្រដាប់អាវុធ ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីឆ្នាំ១៩៩៧-១៩៩៩ និងឆ្នាំ២០០០។

១-ជនជាប់ចោទឈ្មោះ **គស** (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៤ ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៩៣ ផ្លូវ១១១ សង្កាត់អូរឫស្សី១ ខណ្ឌ៧មករា ក្រុងភ្នំពេញ។ ឪពុកឈ្មោះ... ម្តាយឈ្មោះ... ប្រពន្ធឈ្មោះ ...មានកូន០១នាក់ ទោសពីមុនគ្មាន។

-មានមេធាវីលោក ....

២-ជនជាប់ចោទឈ្មោះ **សគ** (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ ៤០ ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ីលក់ដូរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៩៣ ផ្លូវ លេខ១១១ សង្កាត់អូរឫស្សី១ ខណ្ឌ៧មករា ក្រុងភ្នំពេញ។ ឪពុកឈ្មោះ ...ម្តាយឈ្មោះ.... មានកូន០១នាក់ ទោសពីមុនគ្មាន។

-មានមេធាវី ...

-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ **បស** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៩១ ផ្លូវ៩៣ សង្កាត់ផ្សារថ្មីទី៤ ខណ្ឌដូនពេញ ក្រុងភ្នំពេញ។

-មានមេធាវី លោក ...

-តាមពាក្យបណ្តឹង ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០០ របស់ឈ្មោះ **បស** បានបញ្ជាក់ថា កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០០ វេលាម៉ោង១៥ និង ៣០ នាទី ខ្លួនបានឈ្លោះប្រកែកពាក្យសំដីជាមួយឈ្មោះ សគ (**ជូ**) និង ប្តីឈ្មោះ **គស** (**កិះ**) អ្នកលក់នាឡិកាដូចគ្នា ពេលនោះឈ្មោះ **គស** បានគំរាមថា មិនអីទេចាំថ្ងៃស្អែកដឹងហើយ។ លុះថ្ងៃស្អែកឡើង ស្រាប់មានជនប្រដាប់អាវុធមួយក្រុម មានគ្នាពី៧ ទៅ៨នាក់ បានព័ទ្ធតូបរបស់ខ្លួន ហើយគំរាមរកសម្លាប់ពួកខ្លួនពីរនាក់ប្តី

ប្រពន្ធ ថាបើដូចពីមុនឯងដាច់ផ្ទារហើយ ស្របពេល នោះបងប្រុសខ្លួនបានមកដល់ ពួកវាក៏ចេញអស់ទៅ។

-បានឃើញដីកាសម្រេចលេខ៧១០៧ ត.ព្រ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលបានសម្រេចៈ

១-ហាមឃាត់ជនដែលត្រូវចោទទាំងអស់ ទាយាទជនជាប់ចោទ ព្រមទាំងអ្នកដទៃទៀត មិនឱ្យលក់ដូរ ផ្ទេរសិទ្ធិ ជួល បញ្ចាំ ឬធ្វើអំណោយដល់អ្នកដទៃនូវផ្ទះលេខ៩៣Eo ផ្លូវ១១១ សង្កាត់ អូរឫស្សី១ ខណ្ឌ ៧មករា ក្រុងភ្នំពេញ ដែលមានវិញ្ញាបនបត្រលេខ២៣៩៥ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៩១ ជាបណ្តោះអាសន្នរហូតដល់មានការសម្រេចជាថ្មី។

២-បង្គាប់មកមន្ត្រីមានសមត្ថកិច្ចទាំងអស់ដែលពាក់ព័ន្ធអនុវត្តដីកានេះឱ្យមានប្រសិទ្ធភាពតាមច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះ **គស** និងឈ្មោះ **សគ** ប្តឹងមិនសុខចិត្តនឹងដីកាសម្រេចលេខ៧១០៧ ត.ព្រ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ លើដីកាទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថាៈ ក្នុងរឿងនេះជាបទព្រហ្មទណ្ឌពុំទាន់មានសាលក្រម ឬសាលដីការបស់តុលាការចូលជាស្ថាពរណាមួយ ដែលសម្រេចឱ្យជនជាប់ចោទសងសំណងទៅដើមបណ្តឹងឡើយ ហើយតុលាការ បែរជាចេញដីកាឃាត់ទ្រព្យសម្បត្តិរបស់ជនជាប់ចោទបែបនេះមិនត្រឹមត្រូវទេ ដូចនេះ មហាអយ្យការសម្រេចៈ

-បដិសេធដីកាសម្រេចលេខ៧១០៧ ត.ព្រ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០១(ង) ចុះថ្ងៃទី២០ ខែមករា ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចៈ

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះ **គស** និងឈ្មោះ **សគ** ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធដីកាសម្រេចលេខ៧១០៧ ត.ព្រ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ២០០៣ របស់ចៅក្រមតុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣-ទទួលពាក្យសុំដីកាសម្រេច ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះ **បស** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

៤-សាលដីកានេះមានប្រសិទ្ធភាពអនុវត្តភ្លាម ទោះជាមានបណ្តឹងសាទុក្ខក៏ដោយ។

៥-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារជនជាប់ចោទ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

-បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ១១ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះ **បស** ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ០១(ង) ចុះថ្ងៃទី២០ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណាការពារ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ឈ្មោះ **បស** (ជាម្ចាស់បណ្តឹងសាទុក្ខ)ធ្វើឡើងតាមកំណត់ច្បាប់។

-បានឃើញសារណាតប ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ឈ្មោះ **សគ** និង **គស** (ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់។

-បានស្តាប់ថៅក្រមរបាយការណ៍ អានរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖ ក្រោយពីធ្វើការសិក្សាលើសំណុំរឿងរួចមក ឃើញថាបណ្តឹងសាទុក្ខរបស់ឈ្មោះ **បស** ធ្វើឡើងពុំត្រឹមត្រូវតាមច្បាប់។ សាលដីកាសាលាឧទ្ធរណ៍សម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ។

-បានស្តាប់ក្រឡាបញ្ជីអានសាវតាជាតិ និងសារណាការពាររបស់ឈ្មោះ **បស** (ជាម្ចាស់បណ្តឹងសាទុក្ខ)នៅពេលជំនុំជម្រះ។

-បានស្តាប់ក្រឡាបញ្ជីអានសាវតាជាតិ និងសារណាតប របស់ជនជាប់ចោទឈ្មោះ **គស** (ជាចុងបណ្តឹងសាទុក្ខ) ឈ្មោះ **សគ** (ជាចុងបណ្តឹងសាទុក្ខ)នៅពេលជំនុំជម្រះ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី... ជាមេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **បស** នៅពេលជំនុំជម្រះថា៖ ក្នុងនាមខ្ញុំបាទជាមេធាវី ខ្ញុំសូមទាមទារយ៉ាងទទូចចំពោះក្រុមប្រឹក្សាតុលាការកំពូល ដោយសូមឱ្យបដិសេធចោលនូវសាលដីកាលេខ០១(ង) ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ចោលទាំងស្រុង និងសូមតម្កល់ដីកាសម្រេចលេខ៧១០៧ ត.ព្រ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញទុកជាបានការ។ នៅក្នុងនីតិវិធីព្រហ្មទណ្ឌ បណ្តឹងអាចប្តឹងសុំទាំងពីរក៏បានគឺទណ្ឌកម្ម និងសំណង ហើយតុលាការត្រូវសម្រេចទាំងពីរប្រសិនបើជនជាប់ចោទរកឃើញថាមានកំហុស ហើយបណ្តាលឱ្យមានព្យសនៈកម្ម។ ការដែលកូនក្តីខ្ញុំបាទប្តឹងសុំឱ្យឃាត់ទ្រព្យសម្បត្តិរបស់ជនល្មើសនោះ ព្រោះខ្លាចជនល្មើស រត់គេចខ្លួនបាត់ដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្លួន ម្យ៉ាងក៏មានសាលដីកាលេខ១៩ និង២០ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០២ របស់តុលាការកំពូល ដែលមាន

ប្រសិទ្ធភាពរួចទៅហើយ។ អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាតុលាការកំពូល មេត្តាពិចារណាបន្ថែមទៅលើនីតិវិធីនេះព្រោះដីកាសម្រេចរបស់តុលាការក្រុងភ្នំពេញ ដែលសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក......ជាមេធាវីការពារឱ្យជនជាប់ចោទនៅពេលជំនុំជម្រះថាៈ ជាបឋមខ្ញុំបាទ...ជាមេធាវីការពារឱ្យជនជាប់ចោទដែលត្រូវតុលាការក្រុងភ្នំពេញចោទប្រកាន់ពីបទៈប៉ុនប៉ងមនុស្សឃាតដោយគិតទុកជាមុន និងក្រុមជនប្រដាប់អាវុធ សូមគោរពឯកឧត្តមប្រធានក្រុមប្រឹក្សាទាំងមូល។ តាមការលើកឡើងក្នុងសារណារបស់ឈ្មោះ **បស** ខ្ញុំបាទសូមអនុញ្ញាតបង្ហាញជូនទូវដំណើររឿងខ្លះៗ ជូនក្រុមប្រឹក្សាដូចតទៅៈ រឿងក្តីនេះកើតឡើងរវាងឈ្មោះ **បស** និងកូនក្តីខ្ញុំបាទពីរឿង ម៉ូយទិញនាឡិកា ដោយសារមានតូបនៅជិតគ្នា ហើយទំនាស់ក៏កាន់តែរីកធំបន្តិចម្តងៗ ដោយសារបញ្ហាអសន្តិសុខស្រប ពេលដែលមានឃាតករលបធ្វើឃាតខ្លួនឈ្មោះ **បស** ក៏យកលេសចោទទម្លាក់កំហុស មកលើកូនក្តីខ្ញុំបាទតែម្តង តាមពិតឈ្មោះនេះធ្លាប់មានទំនាស់ជាមួយអ្នកផ្សេងៗជាច្រើន។ ក្រោយពីកើត បញ្ហានេះ ឈ្មោះ **បស** ក៏បានប្តឹងទៅតុលាការក្រុង ដោយសុំឱ្យឃាត់ផ្ទះកូនក្តីខ្ញុំបាទ ហើយតុលាការ ក្រុងភ្នំពេញក៏សម្រេចចេញដីកាសម្រេចលេខ៧១០៧ ត,ព្រ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ២០០៣ ដោយហាមឃាត់កូនក្តីខ្ញុំបាទកុំឱ្យលក់ដូរ ឬបញ្ចាំ រឬផ្ទេរ ការសម្រេចនេះមានការខុសឆ្គងយ៉ាងខ្លាំង ដោយបំពានទៅលើមាត្រា៤០ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៩៧-៣៨ ច្បាប់ព្រហ្មទណ្ឌអន្តរកាលនិងច្បាប់ភូមិបាល។ ខ្ញុំបាទសូមសំណូមពរបដិសេធដីកាសម្រេចលេខ៧១០៧ ត.ព្ររបស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ និង តម្កល់សាលដីកាលេខ០១(ង) ចុះថ្ងៃទី២០ ខែមករា ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍ ទុកជាបានការ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់លោក...នៅពេលជំនុំជម្រះថា៖ ច្បាប់រដ្ឋធម្មនុញ្ញ បានការពារសិទ្ធិសេរីភាពបុគ្គលដូចៗគ្នា ចំពោះការសុំវិធានការហាមឃាត់របស់កូនក្តីខ្ញុំ ពុំធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនជាប់ចោទ ពីព្រោះវាជាវិធានការចំបាច់របស់នីតិវិធីច្បាប់ដោយតុលាការកំពូលបានរកឃើញរួចទៅហើយនូវកំហុសឆ្គងនោះ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់លោក...នៅពេលជំនុំជម្រះថា៖ ចំពោះវិធានការដើម្បីគ្រប់គ្រងលើជនជាប់ចោទ គឺមានស្រាប់ទៅហើយ។ ទី១ ជនជាប់ចោទត្រូវទទួលទណ្ឌកម្ម ហើយបើត្រូវចេញសំណង អំពីព្យសនកម្ម ប្រសិនបើមិនសង តុលាការត្រូវចាត់វិធានការតាមផ្លូវច្បាប់។ ដូចជាដាក់គុកបង្ខំលើរូបកាយជាដើម។

-បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលនៅពេលសវនាការថា៖ ពុំមានយោបល់អ្វីបន្ថែមទៀតទេ សូមសម្រេចតាមច្បាប់ចុះ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី សារណារបស់ជនត្រូវចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១១ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ ២០០៤ របស់អ្នកស្រី **បស** ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើក

រឿងនេះមកជំនុំជម្រះបានតាមមាត្រា១៤នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្ដី។

-យល់ឃើញថា ពុំទាន់មានសេចក្ដីសម្រេចណាមួយរបស់តុលាការ ដែលបានសម្រេចផ្ដន្ទាទោសជនត្រូវចោទជាបទអាជ្ញា ដែលមានលក្ខណៈស្ថាពរ ហើយតម្រូវឱ្យជនត្រូវចោទសងព្យសនៈកម្មដល់ជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណីទេ ដូច្នេះការហាមឃាត់រាល់ការចាត់ចែងទ្រព្យសម្បត្តិ របស់ជនត្រូវចោទ ជាការពុំត្រឹមត្រូវទេ។

-យល់ឃើញថា ការលើកឡើងរបស់អ្នកស្រី **បស** ក្នុងសារណាចុះថ្ងៃទីគ្មានខែគ្មានឆ្នាំ២០០៤ ទាមទារសុំឱ្យមានវិធានការបណ្ដោះអាសន្ន ឃាត់ទ្រព្យសម្បត្តិមួយចំនួនរបស់ជនល្មើស ដោយអាងហេតុថា សាលដីកាតុលាការកំពូលលេខ១៩ និងលេខ២០ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០២ មានប្រសិទ្ធភាព អនុវត្តរួចហើយ នោះគឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថាសាលដីកាព្រហ្មទណ្ឌលេខ១៩ និងលេខ២០ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០២ របស់តុលាការកំពូលជាសាលដីកាសម្រេចរឿងមុនអង្គសេចក្ដី ពុំមែនជាសាលដីការឿងអង្គសេចក្ដីស្ថាពរឡើយ។

-យល់ឃើញថា ការដែលលោកមេធាវីដើមបណ្ដឹងលើកឡើងថា ការមិនហាមឃាត់ការចាត់ចែងទ្រព្យសម្បត្តិរបស់ជនជាប់ចោទ នឹងធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់កូនក្ដីលោកនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថាការបិតសិទ្ធិសេរីភាពជនណាមួយ ទោះជាលក្ខណៈបណ្ដោះអាសន្នក៏ដោយ នឹងអាចធ្វើបាននោះ លុះណាតែតម្រូវការចាំបាច់បំផុតនៃប្រយោជន៍ច្បាប់ ឬ ជាប្រយោជន៍សន្ដិសុខសាធារណៈប៉ុណ្ណោះ។

-យល់ឃើញថា ទាំងជនជាប់ចោទ ទាំងដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជម្រះរឿងនេះ កំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ០១(ង) ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីកំបាំងមុខជនជាប់ចោទ**

**និងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ១១ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៤ របស់អ្នកស្រី **បស** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស នឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ០១(ង) ចុះថ្ងៃទី២០ខែមករា ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ១១ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ ២០០៤ របស់តុលាការកំពូលទៅតុលាការក្រុងភ្នំពេញ ដើម្បីបញ្ចូលក្នុងរឿងអង្គសេចក្តី។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០០៦។